# តើអ្វីជាថ្នាំលេបប្រឆាំងវីរុស?

## ថ្នាំគ្រាប់សម្រាប់ជួយបុគ្គលមានផ្ទុកជំងឺ COVID–19 ឱ្យធូរស្បើយ។

ប្រសិនបើអ្នកប្រឈមនឹងហានិភ័យដែលអាចឈឺធ្ងន់ដោយសារជំងឺ COVID-19 ហើយបានធ្វើតេស្តឃើញវិជ្ជមានជំងឺ COVID-19 ក្នុងរយៈពេល 5 ថ្ងៃចុងក្រោយ អ្នកគួរតែពិចារណាលេបថ្នាំគ្រាប់ប្រឆាំងវីរុសតាមវេជ្ជបញ្ជា។ មានថ្នាំព្យាបាលពីរប្រភេទ៖ Paxlovid™ (Pfizer) និង legevirio (Merck)។ អ្នកអាចមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានថ្នាំព្យាបាលជំងឺ COVID-19 មួយក្នុងចំណោមពីរនេះ អាស្រ័យលើអាយុ ប្រវត្តិសុខភាព និងរយៈពេលដែលអ្នកចេញរោគសញ្ញា។

ការប្រើថ្នាំលេបប្រឆាំងវីរុសអាចជួយឱ្យរាងកាយរបស់អ្នកប្រយុទ្ធប្រឆាំងនឹងជំងឺ COVID-19 ដោយរារាំងវីរុស SARS-CoV-2 (វីរុសដែលបង្កឱ្យមានជំងឺ COVID-19) មិនឱ្យបំបែកខ្លួន កាត់បន្ថយចំនួនវីរុសក្នុងរាងកាយ ឬជួយដល់ប្រព័ន្ធភាពស៊ាំរបស់អ្នក។ តាមរយៈការប្រើថ្នាំ អ្នកអាចមានរោគសញ្ញាមិនសូវធ្ងន់ធ្ងរ និងអាចកាត់បន្ថយភាគរយដែលជំងឺរបស់អ្នកប្រែជាធ្ងន់ធ្ងរ ហើយត្រូវការថែទាំក្នុងមន្ទីរពេទ្យ។

---

- ### តើខ្ញុំប្រើថ្នាំលេបប្រឆាំងវីរុសដូចម្ដេច?

ការប្រើថ្នាំលេបប្រឆាំងវីរុសមានន័យថា អ្នកនឹងលេបថ្នាំគ្រាប់។ អ្នកគួរតែប្រើថ្នាំលេបប្រឆាំងវីរុសតាមការណែនាំពីអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក។ កុំលេបរំលង ឬលេបលើសកម្រិតដូស ប្រសិនបើអ្នកខកខានលេបម្ដង។ អ្នកគួរតែលេបថ្នាំព្យាបាលទាំងអស់តាមការណែនាំរហូតដល់អស់ ឬរហូតដល់អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកប្រាប់ឱ្យឈប់។ ថ្នាំលេបប្រឆាំងវីរុសអាចលេបដោយមានឬគ្មានអាហារ ហើយគេណែនាំឱ្យលេបថ្នាំគ្រាប់ទាំងមូល ដោយមិនកាច់ឬកិន។

- ### ចុះបើខ្ញុំមានបញ្ហាសុខភាពស្រាប់ ដូចជាបញ្ហាថ្លើមឬតម្រងនោម?

មុនពេលលេបថ្នាំណាមួយ អ្នកគួរតែពិគ្រោះជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកអំពីប្រវត្តិសុខភាពរបស់អ្នក។ ចំណុចនេះរួមបញ្ចូលទាំងការប្រាប់ពួកគេអំពីបញ្ហាសុខភាពដែលអ្នកប្រហែលជាមានស្រាប់ និងឱសថតាមវេជ្ជបញ្ជា ឱសថតាមហាង វីតាមីន និងអាហារបំប៉នដែលអ្នកកំពុងប្រើ។

បុគ្គលដែលមានបញ្ហាថ្លើមឬតម្រងនោមគួរតែពិគ្រោះជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពអំពីបញ្ហាសុខភាពរបស់ខ្លួន មុនពេលលេបថ្នាំប្រឆាំងវីរុសណាមួយ។ អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកអាចសម្រេចថា

ការប្រើថ្នាំលេបប្រឆាំងវីរុសសមស្របសម្រាប់អ្នក ឬកម្រិតដូសរបស់អ្នកសមស្របឬអត់។ ថ្នាំព្យាបាលមួយចំនួនអាចនឹងមិនត្រូវបានណែនាំឱ្យប្រើសម្រាប់បុគ្គលដែលមានបញ្ហាសុខភាពជាក់លាក់ទេ។

- ## ចុះបើខ្ញុំគ្មានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីប្រើថ្នាំលេបប្រឆាំងវីរុស?

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចសម្រេចថាអ្នកគ្មានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីប្រើថ្នាំលេបប្រឆាំងវីរុស ឬថាវាមិនសមស្របសម្រាប់អ្នកឬអត់។ អាចមានមូលហេតុច្រើនសម្រាប់ករណីនេះ។ អ្នកប្រហែលជាមិនបំពេញតាមលក្ខខណ្ឌទាំងអស់ ឬអ្នកប្រហែលជាមានបញ្ហាសុខភាពដែលអាចនឹងមិនសមស្របសម្រាប់ការព្យាបាលជាក់លាក់។ សូមពិគ្រោះជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអំពីជម្រើសព្យាបាលប្រសើរបំផុតសម្រាប់អ្នក។

Washington State Department of Health

DOH 825-029 May 2022 Khmer

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ mailto:ecivil.rights@doh.wa.gov។